សម្លេងខ្មែរនៅបរទេស

# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិត
## ហុក-សាវណ្ណ
## អំពីព្រះសង្ឃព្រះពុទ្ធសាសនាថេរវាទ
## ជាមួយនិងនយោបាយ

តាមការស្រាវជ្រាវ ពាក្យថានយោបាយ តាមវចនានុក្រមភាសាបារាំងនិងអង់គ្លេសមានន័យទូទៅថា ការយល់ស្របតាមមាគ៌ាដែលអនុវត្តមានន័យមួយទៀតថា នយោបាយបានដល់របៀបចាត់ការខាងសេដ្ឋកិច្ចសង្គមកិច្ច និងកិច្ចការទូត ។ ក្នុងសៀវភៅ Encyclopedia ទាំងបារាំងទាំងអង់គ្លេសមានចំណុចមួយពោលថា កិច្ចការគ្រប់យ៉ាងដែលគេធ្វើជាមួយសង្គម ហៅថានយោបាយ ។ តាមវចនានុក្រមខ្មែរ នយោបាយមកពីនយ: និង ឧបាយ: មានសេចក្តីថា ឧបាយក្នុងការណែនាំ កលល្បិចឬមេគំនិតដែលផ្តើមឡើងសំរាប់ដឹកនាំអ្នកដទៃឲ្យប្រព្រឹត្តធ្វើ ដើម្បីគោលដៅអ្វីមួយ ។ តាមន័យដែលបានយោងខ្លះតាមប្រភពផ្សេងៗគ្នានេះបញ្ជាក់ថា នយោបាយបានដល់របៀបកិច្ចការគ្រប់យ៉ាង ដែលបុគ្គលបានធ្វើដើម្បីដឹកនាំជីវិតខ្លួន និងរបៀបកិច្ចការរបស់សង្គម ។ គេច្រើនប្រើពាក្យនយោបាយនេះ ចំពោះទៅលើកិច្ចការ ដែលទាក់ទងនឹងការគ្រប់គ្រងរដ្ឋ ។ ប៉ុន្តែខ្មែរមានប្រើពាក្យនេះថា នយោបាយគ្រួសារ នយោបាយទឹកជាដើម ។

របៀបដឹកនាំរបស់មនុស្សក្នុងសង្គម គេប្រើវិធីប្រើរបៀបនិងកលល្បិចច្រើនយ៉ាង រាប់បញ្ចូលទាំងវិធីហឹង្សាគំរាមកំហែងផង ។ ចំណែកព្រះពុទ្ធសាសនាវិញ ព្រះពុទ្ធមួយអន្លើដោយព្រះសង្ឃ បានណែនាំមនុស្សនិងសង្គមមនុស្ស ទៅតាមនិស្ស័យរបស់គេ គឺទៅតាមសទ្ធា របៀបឬវិធីណែនាំនោះ គឺជាការបង្ហាញហេតុផលល្អអាក្រក់សំរាប់ឲ្យមនុស្សនិងសង្គមមនុស្សជ្រើសរើសផ្លូវអនុវត្តដោយខ្លួនឯង ដោយគ្មានការបង្ខិតបង្ខំ ឬគ្មានការលាក់អាថ៌កំបាំងល្បិចកិច្ចកលអាក្រក់ណាមួយ ក្នុងគោលដៅព្យាបាទអ្នកដទៃឡើយ ។

ផ្ទុយទៅវិញ ព្រះពុទ្ធបង្រៀនឲ្យមនុស្សលះអំពើអាក្រក់ ហើយហាត់រៀនធ្វើល្អ ដូចបាលីថាកុសលាធម្មា ក្រុមធម៌ជាកុសលត្រូវកាន់យកគឺត្រូវអនុវត្ត អកុសលាធម្មា ក្រុមធម៌ជាអកុសល ត្រូវលះបង់ គឺកុំធ្វើជាដើម ។ ដូច្នេះវិធីរបស់ព្រះពុទ្ធសាសនា ជាវិធីសន្តិភាពដោយប្រើធម៌អហឹង្សា ការពុំបៀតបៀនក្នុងការណែនាំមនុស្សនិងសង្គមមនុស្សទៅរកសុខសន្តិភាព ។ តាមន័យនេះ គេពុំអាចយកពាក្យនយោបាយតាមពាក្យផ្លូវលោក ដែលមានន័យច្របូកច្របល់ មកប្រើក្នុងពុទ្ធសាសនាបានឡើយ ព្រោះនាំឲ្យគេយល់ច្រឡំក្នុងការអនុវត្តន៍ក្នុងលោកនិងផ្លូវធម៌ ។ បើប្រើពាក្យថា ព្រះពុទ្ធឬព្រះសង្ឃបានធ្វើនយោបាយទេសនាពន្យល់ណែនាំមនុស្ស ជាពាក្យដែលស្តាប់មើលទៅ ហាក់ដូចព្រះសង្ឃទេសនាលាយទៅដោយពាក្យឃោសនាបង្ខិតបង្ខំ ស្តាប់ទៅពុំពិរោះត្រចៀក ព្រោះជាពាក្យគេពុំធ្លាប់ប្រើ ។

ទោះបីពេលខ្លះ ព្រះសង្ឃសំដែងធម៌ ដោយប្រើឧមាណវិធី គឺការប្រៀបធៀប ឬប្រើល្បិចខ្លះ ក៏ដើម្បីឲ្យមនុស្សសត្វយល់ព្រះធម៌ប៉ុណ្ណោះពុំមែនដូចល្បិចផ្លូវ លោកធ្វើឡើងដើម្បីបំផ្លាញគ្នាឡើយ ។ ក្នុងសម័យពុទ្ធកាល មានសកម្មភាពជាច្រើន ដែលព្រះអង្គយាងទៅជួយសម្រួលជម្លោះអ្នកនយោបាយ ។ នៅថ្ងៃមួយ ព្រះពុទ្ធបានយាងទៅឃាត់ព្រះញាតិរបស់ព្រះអង្គពីរក្រុម ដែលទាស់ទែងខ្វែងគំនិតគ្នា អំពីការបង្ហូរទឹកស្ទឹងរោហិណីដាក់ស្រែរបស់ខ្លួន ដោយព្រះញាតិទាំងសងខាងប្រកាន់ថាជាទឹកស្ទឹងរបស់ខ្លួន ជម្លោះនេះមានភាពខ្លាំងក្លា កំពុងប្រឈមមុខដាក់គ្នា បំរុងធ្វើសង្គ្រាមបង្ហូរឈាមគ្នា, ព្រះអង្គបានយាងទៅដល់ មានព្រះពុទ្ធដីកាលាយដោយការរំលឹកផងថា ម្នាលព្រះញាតិទាំងសងខាង តើព្រះអង្គម្ចាស់ទាំងសងខាងបង្ហូរទឹកស្រែឬបង្ហូរឈាមល្អជាង ព្រះអង្គបន្តព្រះពុទ្ធដីកាទៀតថា តាមតថាគតយល់ គួរព្រះញាតិទាំងសងខាងសំរួលគ្នា ចែកទឹកស្រែគ្នាប្រើទៅ កុំបង្ហូរឈាមគ្នា ដែលនាំឲ្យប្រជាពលរដ្ឋទាំងសងខាងទទួលរងគ្រោះ ដោយសារតែព្រះញាតិថ្នាក់លើពុំចេះសម្រួលគ្នា ជៀសវាងអំពើហឹង្សា ។

ពេលនោះ ដោយការគោរពព្រះពុទ្ធផង ដោយឱវាទដ៏មានខ្លឹមសារប្រកបដោយសច្ចធម៌របស់ព្រះពុទ្ធផង និងគិតឃើញកំហុសរបស់ខ្លួនផង ព្រះញាតិទាំងសងខាងក៏ស្រុះស្រួលគ្នា តាមការណែនាំរបស់ព្រះអង្គ រួចថ្វាយបង្គំថយចេញរៀងខ្លួនទៅ ពុំបានបង្ហូរឈាមគ្នាឡើយ ។ នេះជាអន្តរាគមន៍របស់ព្រះពុទ្ធ ចំពោះអ្នកនយោបាយពីរក្រុម កុំឲ្យបង្ហូរឈាមគ្នា ។ ព្រះសង្ឃខ្មែរបច្ចុប្បន្ន ក៏អាចបំពេញមុខនាទីនេះបាន ឲ្យតែអ្នកនយោបាយសុទ្ធចិត្តទទួលស្គាល់ និងឲ្យតម្លៃសកម្មភាពបែបនេះ ។ ព្រះសង្ឃអាចណែនាំគ្រហស្ថក្នុងផ្លូវល្អផ្លូវត្រូវបាន ដើម្បីឲ្យសង្គមកម្ពុជាបានសុខសន្តិភាព ។ ព្រះសង្ឃនិងគ្រហស្ថជិះលើនាវាមួយជាមួយគ្នា បើព្រះសង្ឃឃើញនាវានោះមានរន្ធទឹកចូល លោកអ្នកប្រាប់អ្នកជិះនាវាទាំងអស់ឲ្យចុករន្ធ កុំឲ្យទឹកចូលលិចស្លាប់ទាំងអស់គ្នា ។ យ៉ាងណាមិញ នាវាទុកដូចប្រទេសកម្ពុជា, អ្នកនៅប្រទេសកម្ពុជា គឺព្រះសង្ឃនិងគ្រហស្ថត្រូវតែព្រួតដៃគ្នារក្សាការពារប្រទេសកម្ពុជាឲ្យបានគង់វង់ស្ថិតស្ថេរ តាមមុខងារនាទីរៀងខ្លួន ។

ព្រះថេរដីការបស់សម្តេចព្រះសង្ឃរាជ ជួន-ណាត ថ្លែងក្នុងឱកាសអនុសំវច្ឆរ:មហាសន្និបាតនៃមន្ត្រីសង្ឃមុនឆ្នាំ១៩៧០ នៅក្នុងព្រះវិហារជាន់ក្រោមនៃវត្តឧណ្ណាលោមថា យើងជាព្រះសង្ឃពុំអាចធ្វើនយោបាយឲ្យដូចគេជាគ្រហស្ថបានទេ តែយើងអាចឲ្យយោបល់ដល់អ្នកដឹកនាំរដ្ឋគ្រប់ជាន់ថ្នាក់ តាមផ្លូវធម៌អាថ៌បាន គ្មានទាស់ខុសវិន័យបញ្ញត្តិរបស់ព្រះពុទ្ធឡើយ ទុកជាការជួយតម្រែតម្រង់ផ្លូវ កុំឲ្យមានគ្រោះថ្នាក់ដល់ជាតិនិងពុទ្ធសាសនា ព្រោះជាតិនិងសាសនាស្ថិតនៅជាមួយគ្នា ។

ព្រះសម្ពុទ្ធសំដែងធម៌ទេសនាប្រោសសត្វជាទូទៅ ទាំងអ្នកមានទាំងអ្នកក្រ ទាំងអ្នកធំទាំងអ្នកតូច គឺទាំងប្រជាពលរដ្ឋទាំងអ្នកដឹកនាំរដ្ឋដែលកាន់ការនយោបាយគ្រប់ប្រភេទ ដូចជាព្រះអង្គសំដែងធម៌ទេសនាប្រោសព្រះមហាក្សត្រសោយរាជ្យ គឺព្រះបាទពិម្ពិសារ ព្រះបាទបសេនទិកោសល ឲ្យមានទសពិធរាជធម៌ ដឹកនាំរដ្ឋឲ្យលុះក្នុងគន្លងធម៌ ។ ព្រះអង្គសំដែងធម៌ប្រោសសេដ្ឋីគហបតីអ្នកមានទ្រព្យសម្បត្តិច្រើនដូចជា អនាថបិណ្ឌិកសេដ្ឋី នាងវិសាខាជាដើម។ ដូច្នេះបញ្ជាក់ថា ព្រះពុទ្ធពុំមែនសំដែងធម៌ចំពោះតែប្រជាពលរដ្ឋសាមញ្ញទេ គឺព្រះអង្គសំដែងប្រោសមនុស្ស

គ្រប់ប្រភេទ រួមទាំងអ្នកនយោបាយផង ។ ពិសេសព្រះអង្គចាប់អារម្មណ៍ អ្នកនយោបាយខ្លាំងជាងគេបំផុត ព្រោះអ្នកមានអំណាច បើគ្មានធម៌ក្នុងខ្លួនទេ អាចយកអំណាចខ្លួន ទៅធ្វើបាបជិះជាន់អ្នកតូចទាបជាងខ្លួន ។

ពេលត្រាស់ដឹងភ្លាម ព្រះអង្គពិចារណាឃើញថា ជនបីក្រុមអាចធ្វើឲ្យសង្គមចំរើនលូតលាស់ បើក្រុមនោះមានធម៌ក្នុងខ្លួន បើគ្មានធម៌ក្នុងខ្លួនទេ អាចធ្វើឲ្យសង្គមវិនាសអន្តរាយ ។ ជនទាំងបីក្រុមនោះគឺ ក្រុមបញ្ញវ័ន្ត, ក្រុមឥស្សរជនអ្នកមានអំណាច និងក្រុមអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ ។ ក្រុមបញ្ញវ័ន្តដែលគេសន្មត់ថា ជាអ្នកមានបញ្ញា ជាអ្នកមានចំណោះខ្ពស់ តែជាអ្នកចេះដឹងផ្លូវខុស ដូចជាទ្រឹស្តីលទ្ធិកុម្មុយនិស្ត ហើយយកទ្រឹស្តីខុសបែកឆ្វេងមិច្ឆាទិដ្ឋិនោះទៅអនុវត្តក្នុងសង្គម នឹងធ្វើឲ្យសង្គមវិនាសអន្តរាយ ដូចជាពួកខ្មែរក្រហម ដែលមានខ្លះមានសញ្ញាប័ត្រថ្នាក់បណ្ឌិត ប៉ុន្តែធ្វើឲ្យប្រជាពលរដ្ឋខ្មែរស្លាប់ស្ទើរពាក់កណ្តាលនគរ ។ ក្រុមឥស្សរជនអ្នកមានអំណាច បើមិនយកអំណាចរបស់ខ្លួនទៅបំរើសង្គមទេ បែរជាយកអំណាចរបស់ខ្លួន ទៅជិះជាន់សង្កត់សង្កិនសង្គម ដែលសព្វថ្ងៃហៅថាប្រើលទ្ធិផ្តាច់ការ នោះនឹងធ្វើឲ្យសង្គមវិនាស ។ ក្រុមអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភក៏ដូចគ្នា បើគ្មានធម៌គឺសេចក្តីល្អប្រកបដោយមេត្តាធម៌ជាដើមក្នុងខ្លួនទេ នឹងយកទ្រព្យសម្បត្តិទៅប្រើជាមធ្យោបាយធ្វើបាបអ្នកដទៃ ។ ព្រះពុទ្ធបានសំដែងធម៌ប្រោសមនុស្ស៣ក្រុម នេះជាដំបូង មុននឹងទៅសំដែងធម៌ទេសនាប្រោសអ្នកដទៃទៀត ដូចព្រះអង្គប្រោសភិក្ខុ៥អង្គ ដែលជាបញ្ញវ័ន្តសម័យនោះ ដើម្បីឲ្យភិក្ខុ៥អង្គនោះយល់ត្រូវជាសម្មាទិដ្ឋិ ក្នុងវិធីប្រតិបត្តិ ដើម្បីចេញចាកទុក្ខ ហើយបានជាសហការីក្នុងការសំដែងធម៌ទេសនាប្រោសសត្វ ។

ព្រះសង្ឃព្រះពុទ្ធសាសនាមហាយាន មានព្រះវិន័យធូរជាងព្រះសង្ឃព្រះពុទ្ធសាសនាថេរវាទ ។ ព្រះសង្ឃព្រះពុទ្ធសាសនាមហាយានអាចធ្វើការរកស៊ីដូចជាគ្រហស្ថ ដូចជាព្រះសង្ឃជាតិជប៉ុន ព្រះសង្ឃជាតិចិនតៃវ៉ាន់ជាដើម, អាចធ្វើនយោបាយកាន់ការរដ្ឋដូចជាគ្រហស្ថ ដូចសម្តេចដាឡៃឡាម៉ានៃប្រទេសទីបេត៍ មានមុខតំណែងជាសម្តេចសង្ឃខាងពុទ្ធចក្រផង និងជាប្រមុខដឹកនាំនយោបាយខាងផ្លូវអាណាចក្រផង ។

សរុបសេចក្តីមក, មានជនជាតិខ្លះ បើកាលណាព្រះសង្ឃមានថេរដីការិះគន់ អ្នកកាន់ការរដ្ឋដែលប្រព្រឹត្តខុស តែងពោលថាព្រះសង្ឃមានថេរដីកានយោបាយ ប៉ុន្តែបើព្រះសង្ឃពោលសរសើរអ្នកកាន់ការរដ្ឋទោះបីអ្នកកាន់ការរដ្ឋនោះប្រព្រឹត្តខុសក៏ដោយ មិនចោទព្រះសង្ឃថាមានថេរដីកានយោបាយឡើយ ។ នេះមកអំពីជននោះពុំយល់អំពីមុខងារព្រះសង្ឃក្នុងសង្គម ឬក៏យល់ដែរប៉ុន្តែប្រើវិធីបង្ក្រាប បំបាក់ស្មារតីកុំឲ្យព្រះសង្ឃរិះគន់ត្រង់កន្លែងណា ដែលជាចំណុចខ្សោយរបស់ពួកគេ ដោយបិទបាំង កុំឲ្យការពិតនេះដឹងដល់ប្រជាពលរដ្ឋ ។ ព្រះសង្ឃក៏ជាខ្មែរ លោកមានសិទ្ធិបញ្ចេញយោបល់ក្នុងបញ្ហាជាតិ ដើម្បីជួយរំលែកការពារជាតិមាតុ ភូមិ តាមឋានៈលោកជាព្រះសង្ឃដែរ ។ ដូចពោលមកហើយ ព្រះពុទ្ធពុំមែនព្រះអង្គទេសនាប្រោសតែមនុស្សតូចតាច ឥតបុណ្យឥតស័ក្តិក្រីក្រទ្រព្យសម្បត្តិនោះឡើយ គឺព្រះអង្គប្រោសគ្រប់ឋានៈមនុស្សទាំងអស់ ពិសេសអ្នកនយោបាយ ព្រោះព្រះអង្គយល់ថា បើអ្នកនយោបាយពុំមានធម៌នៅក្នុងខ្លួន គឺពុំប្រព្រឹត្តមានធម៌ ដែលធ្វើឲ្យខ្លួនទៅជាអ្នកដឹកនាំទេ អ្នកនយោបាយនោះនឹងដឹកនាំសង្គមទៅរកសេចក្តីវិនាស ។ គំនិតដូចគ្នានេះដែរ សម្តេចព្រះសង្ឃរាជ ជួន-ណាត ក៏មានថេរដីកាថា ព្រះសង្ឃអាចឲ្យយោបល់ដល់អ្នកដឹកនាំរដ្ឋគ្រប់ជាន់ថ្នាក់បាន ពុំទាស់ខុសនឹងវិន័យបញ្ញត្តិរបស់ព្រះពុទ្ធឡើយ។ តាមពិតធ្វើអ្វីក៏ត្រូវប្រើមធ្យោបាយដែរ ដើម្បីឲ្យសំរេចគោលដៅ ប៉ុន្តែគ្រាន់តែមធ្យោបាយរបស់ព្រះពុទ្ធសាសនា ជាមធ្យោបាយសន្តិវិធី ប្រកបដោយអហិង្សាការពុំបៀតបៀនចំណែកមធ្យោបាយផ្លូវលោកដែល ហៅថានយោបាយប្រើសន្តិវិធីខ្លះយុទ្ធវិធីខ្លះប៉ុណ្ណោះ ។៚